# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្ដីប្រកាសព័ត៌មាន

ថ្ងៃទី១០ ខែ មិនា ឆ្នាំ២០១៦

## ជប៉ុនផ្ដល់ថវិកាសរុបចំនួន ២៦៣,៦៥៥ ដុល្លារអាមេរិក សម្រាប់ការស្ដារប្រព័ន្ធធារាសាស្ត្រប្រឡាយក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង និងការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្ម ក្នុងខេត្តព្រះវិហារ

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន ផ្ដល់ថវិកាសរុបចំនួន២៦៣,៦៥៥ ដុល្លារអាមេរិក ដល់មន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបង មន្ទីរកសិកម្មខេត្តព្រះវិហារ និងមន្ទីរធនធានទឹកនិងឧតុនិយមខេត្តស្វាយរៀង។ កិច្ចសន្យាផ្ដល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ**ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបីសម្រាប់គម្រោងដូចតទៅៈ

**១. គម្រោងស្ដារឡើងវិញប្រព័ន្ធធារាសាស្ត្រប្រឡាយយោធា ក្នុងខេត្តបាត់ដំបង (ថវិកាចំនួន៨៩,៣៩២ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយៈ មន្ទីរធនធានទឹក និងឧតុនិយមខេត្តបាត់ដំបង

គម្រោងទីមួយនេះ គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានថវិកាសរុបចំនួន ៨៩,៣៩២ដុល្លារអាមេរិក។ គម្រោងនេះរួមមានៈ ការស្ដារប្រឡាយ១ខ្សែប្រវែង១,៤០០ម៉ែត្រ ការសាងសង់សំណង់ក្បាលប្រឡាយ១កន្លែង និងសំណង់ស្ទាក់ទឹកលើប្រឡាយ១កន្លែង។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយសម្រួលដល់ការទទួលបានទឹកសម្រាប់ស្រោចស្រពលើដីស្រែរបស់ប្រជាកសិករប្រមាណជា៧០០នាក់ បន្ទាប់ពីគម្រោងនេះ ត្រូវបានបញ្ចប់។

**២. គម្រោងសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្ម ក្នុងខេត្តព្រះវិហារ (ថវិកាចំនួន ៨៤,៦៦២ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយៈ មន្ទីរកសិកម្មខេត្តព្រះវិហារ

គម្រោងទីពីរនេះ គឺដើម្បីជួយដល់មន្ទីរកសិកម្មខេត្តសម្រាប់ការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្ម ក្នុងខេត្តព្រះវិហារ ដែលមានថវិកាសរុបចំនួន ៨៤,៦៦២ដុល្លារអាមេរិក។ នៅក្នុងគម្រោងនេះ នឹងធ្វើការសាងសង់មជ្ឈមណ្ឌលសហគមន៍កសិកម្មចំនួន៣កន្លែង ព្រមទាំងផ្ដល់នូវម៉ាស៊ីនកសិកម្មជាច្រើនគ្រឿងរួមមានៈ គោយន្តចំនួន៣គ្រឿង ម៉ាស៊ីនបោកស្រូវចំនួន២គ្រឿង ម៉ាស៊ីនបោកសណ្ដែកចំនួន១គ្រឿង និងឡសម្ងួតស្រូវ១គ្រឿង ដើម្បីផ្ដល់ជូនដល់សហគមន៍កសិកម្មចំនួន៣។ គម្រោងនេះត្រូវបានរំពឹងថា នឹងផ្ដល់អត្ថប្រយោជន៍ដល់ប្រជាកសិករប្រមាណជា៨៨០នាក់ ពីសហគមន៍កសិកម្មទាំងបីនេះ។

**៣. គម្រោងស្ដារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រប្រឡាយទំនប់លោក ក្នុងខេត្តស្វាយរៀង (ថវិកាចំនួន ៨៩,៦០១ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយៈ មន្ទីរធនធានទឹក និងឧតុនិយមខេត្តស្វាយរៀង

គម្រោងទីបីនេះ គឺដើម្បីពង្រីកផ្ទៃដីស្រោចស្រពក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដែលមានថវិកាសរុបចំនួន៨៩,៦០១ ដុល្លារអាមេរិក។ គម្រោងនេះរួមមានៈ ការស្ដារប្រឡាយមេ១ខ្សែប្រវែង១,៤២០ម៉ែត្រ និងសំណង់ស្ទាក់ទឹក១កន្លែង។ យើងសង្ឃឹមថាគម្រោងនេះ នឹងជួយសម្រួលដល់ការទទួលបានទឹកស្រោចស្រពសម្រាប់ដីស្រែរបស់ប្រជាកសិករប្រមាណជា ១,៦៧០នាក់ បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។

*ជំនួយឥតសំណងគូសាណូណោរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង៥៤លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណោចំនួន៥៤៧ គម្រោង ។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*